

*អ្វីៗទាំងអស់មានសំឡេងឮខ្លាំងណាស់ ។ តើឲ្យ លូក អាចរកភាពសុខសាន្តបាននៅឯណាទៅ ?*

# ថ្លង់ខ្លាំងណាស់ !

ដោយ រីឆាត មិម រ៉មនី
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

លូក បានគ្រូញក្ដែរ ។ អ្វីៗទាំងអស់មានសំឡេងឮខ្លាំងណាស់ ។ បងប្រុសរបស់គាត់ ចាត និង ចន ឈ្លោះគ្នាទៀតហើយ ។ សូម្បីតែនៅផ្លូវដើរខាងក្រៅបន្ទប់ ក៏គាត់អាចឮពួកគេស្រែកដាក់គ្នាឆ្លងបន្ទប់ដែរ ។ ហើយបងស្រីរបស់គាត់ លីហ្ស៊ី វិញ លេងតន្ត្រីរបស់គាត់បើកសំឡេងឡើងឮខ្លាំងទៀតហើយ ។ ទឹម ។ ទឹម ។ ទឹម ។ គាត់អាចឮសំឡេងភ្លេងរណ្ដំឥតដាច់ជានិច្ច ។

លូក បានព្យាយាមសូមឲ្យបងប្រុសរបស់គាត់ឈប់ឈ្លោះគ្នា ។ ចាត បានប្រាប់គាត់ថា « ចេញឲ្យឆ្ងាយ » ។ បន្ទាប់មក លូក បានសូមឲ្យ លីហ្ស៊ី បន្ថយសំឡេងតន្ត្រីរបស់គាត់ ។ តែនាងបែរជាបើកសំឡេងកាន់តែឮថែមទៀត ។

លូក ចង់ចេញក្រៅ ទៅកន្លែងដែលគាត់អាចគិតបាន ។ ប៉ុន្តែវាភ្លៀង ។

តែយ៉ាងហោចណាស់ មានកន្លែងស្ងប់ស្ងាត់មួយដែល លូក អាចទៅបាន ។ ម្សិលមិញឪពុកម្ដាយរបស់គាត់បានឲ្យបន្ទប់ផ្ទាល់ខ្លួនមួយទៅគាត់ —ជាបន្ទប់ដែលគាត់មិនចាំបាច់នៅជាមួយ ចាត និង ចន ឡើយ ។ វានៅជាន់ក្រោមដី ។ វាធំល្មមសម្រាប់តែគ្រែ និងតុមួយប៉ុណ្ណោះ ។ ប៉ុន្តែនៅក្នុងបន្ទប់របស់គាត់ លូក អាចបិទទ្វារ និងគេចចេញពីសំឡេងទាំងនោះបាន ។

លូក បានចុះក្រោមទៅកាន់បន្ទប់ថ្មីរបស់គាត់ ។ គាត់បានមើលជុំវិញប្រអប់ទាំងឡាយ ដែលគាត់បានយកចុះពីលើកមុន ។ គាត់បានឃើញរូបភាពព្រះយេស៊ូវមួយលៀនចេញពីប្រអប់មួយ ។ លូក បានទទួលរូបភាពនោះនៅថ្ងៃដែលគាត់បានជ្រមុជទឹក ។ ពេលមើលទៅរូបភាពនោះធ្វើឲ្យគាត់មានអារម្មណ៍សុខសាន្តជានិច្ច ។



លូក បានយករូបភាពនោះចេញពីប្រអប់ ។ គាត់បានដាក់វានៅលើតុ ។ បន្ទាប់មក គាត់បានលុតជង្គង់ចុះអធិស្ឋាន ។ លូក បានពោលថា « ឱ ព្រះវរបិតាសួគ៌អើយ ពេលខ្លះវាថ្លង់ខ្លាំងណាស់នៅទីនេះ ។ សូមជួយកូនឲ្យទទួលបានសេចក្ដីសុខសាន្តខ្លះផង » ។

លូក បានទម្រេតនៅលើគ្រែរបស់គាត់ ។ គាត់បានគិតអំពីព្រះយេស៊ូវ ។ គាត់បានរៀននៅក្នុងថ្នាក់កុមារថា ព្រះយេស៊ូវតែងតែអាចគង់នៅជិតគាត់ជានិច្ច ។ ហើយព្រះវិញ្ញាណបរិសុទ្ធអាចនាំសេចក្ដីសុខសាន្តដល់យើងជានិច្ចដែរ ។

បន្តិចទៀត ម៉ាក់ និងប៉ានឹងមកដល់ផ្ទះវិញពីធ្វើការ ។ ពួកគាត់នឹងនិយាយជាមួយ ចាត និង ចន ។ ការឈ្លោះគ្នានេះនឹងបញ្ឈប់ ។ មួយរយៈ ។ ពួកគាត់នឹងនិយាយជាមួយ លីហ្ស៊ី ។ លីហ្ស៊ី នឹងបន្ថយសំឡេងតន្ត្រីរបស់គាត់ ។ មួយរយៈ ។ រហូតដល់ម៉ាក់ និងប៉ាចេញទៅធ្វើការម្ដងទៀត ។

ប៉ុន្តែសម្រាប់ពេលនេះ លូក បានសម្រាកនៅលើគ្រែ ។ គាត់បានសម្លឹងមើលរូបភាពព្រះយេស៊ូវ ។ លូក បាននិយាយខ្សឹបៗថា « ឱ ព្រះវរបិតាសួគ៌ សូមមេត្តា ។ សូមជួយកូនឲ្យមានអារម្មណ៍សុខសាន្ត មិនថាមានអ្វីកើតឡើងនៅក្នុងផ្ទះនេះទាំងមូលនោះទេ » ។

ក្រោយមក មានសំឡេងគោះទ្វារនៅបន្ទប់គេងគាត់ ។ ម៉ាក់សួរថា « តើម៉ាក់អាច ចូលបានទេ ? តើកូនយ៉ាងម៉េចហើយ ? »

លូក បានតបថា « ចាត និង ចន ឈ្លោះគ្នាទៀតហើយ ។ ហើយ លីហ្ស៊ី វិញ ចាក់តន្ត្រីគាត់បើកសំឡេងឡើងឮខ្លាំងទៀត » ។

ម៉ាក់បាននិយាយថា « ម៉ាក់ដឹង ។ វាពិបាកណាស់ ។ ត្រូវទេ ? ប៉ាកំពុងនិយាយជាមួយបងប្រុសរបស់កូននៅពេលនេះហើយ ។ ហើយម៉ាក់នឹងនិយាយជាមួយ លីហ្ស៊ី នៅយប់នេះ ។ ប៉ុន្តែដំបូង ម៉ាក់ចង់ដឹងថា តើកូនសុខទុក្ខយ៉ាងណាហើយ » ។

លូកបានតបថា « កូនមិនអីទេ ។ កូនសប្បាយចិត្ត ដែលកូនមានបន្ទប់នេះ » ។

ម៉ាក់បាននិយាយថា « ម៉ាក់ក៏អឺចឹងដែរ ។ ម៉ាក់ឃើញកូនដាក់រូបភាពព្រះយេស៊ូវនៅលើតុ » ។

លូកា ញញឹម ។ « បាទ ម៉ាក់ ។ ហើយទ្រង់នឹងជួយកូនធ្វើឲ្យបន្ទប់របស់កូន ជាកន្លែងមួយដែលមានសេចក្ដីសុខសាន្ត » ។●

ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អ. ។

**សូមសរសេរ ឬគូររូបភាពពីរបៀបដែលប្អូនៗអាចមានអារម្មណ៍សុខសាន្តនៅក្នុងផ្ទះរបស់ប្អូនៗ ។**